**សេចក្តីប្រកាសព័ត៌មាន**

**ថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០១០**

# ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោកៈ
# សន្តមសុីវិលអំពាវនាវឱ្យមានសកម្មភាពបរិស្ថានវិជ្ជមាន
# ដើម្បីការពារជីវៈចម្រុះតាមរយៈបច្ចេកវិទ្យាថាមពលស្អាត

*ខេត្តព្រះសីហនុ* - ក្នុងឱកាសនៃទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោកឆ្នាំ ២០១០ បណ្តាញវេទិកាបរិស្ថាន របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) ដោយសហការជាមួយក្រសួងបរិស្ថាន មន្ទីរបរិស្ថាននៃខេត្តព្រះសីហនុ និង បណ្តាញតស៊ូមតិនៃអង្គការមិនមែនរដ្ឋាភិបាលខេត្តព្រះសីហនុ (SNAN) នឹងប្រារព្ធធ្វើពិធីអបអរសាទរជីវៈចម្រុះដ៏សម្បូណ៌បែបរបស់កម្ពុជា និង ភាពចាំបាច់ត្រូវមានការអភិរក្សបរិស្ថាន ក្រោមប្រធានបទ **"មនុស្ស សត្វទាំងអស់ ភពផែនដីតែមួយ អនាគតតែមួយ"** នៅក្នុងព្រឹត្តិការណ៍បង្កើនការយល់ដឹងសាធារណៈមួយដែលត្រូវបានប្រារព្ធធ្វើនៅឆ្នេរអូរឈើទាល ខេត្តព្រះសីហនុ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១០។ ព្រឹត្តិការណ៍ឆ្នាំនេះ នឹងមាន ប្រារព្ធពិធីអបអរសាទរ ពិពិធភាពដ៏អស្ចារ្យនៃផែនដី ជាផ្នែកមួយនៃឆ្នាំអន្តរជាតិនៃជីវៈចម្រុះឆ្នាំ២០១០។ ប្រជាជនរាប់លាននាក់នៅជុំវិញពិភពលោក ប្រារព្ធទិវានេះ ដោយបង្កើតឱ្យមានព្រឹត្តិការណ៍ជាច្រើនសារ ដើម្បីអបអរសាទរទិវានេះ ដោយសារតែទិវានេះ ជាទិវាដើម្បីសកម្មភាពបរិស្ថាន។

ព្រឹត្តិការណ៍នេះ នឹងជម្រុញឱ្យសាធារណជននិងអ្នកធ្វើគោលនយោបាយកម្ពុជា ដៃគូអភិវឌ្ឍន៍ និង ផ្នែកឯកជនប្រកាន់យកជំហានដ៏ក្លាហានឆ្ពោះទៅកាន់ ការគ្រប់គ្រងជីវៈចម្រុះ និងធនធានធម្មជាតិនៅប្រទេសកម្ពុជា ក្នុងលក្ខណៈ ប្រកបដោយនិរន្តរភាពនិងសមធម៌ តាមរយៈការជម្រុញឱ្យប្រើបច្ចេកវិទ្យាថាមពលស្អាត និង ការផលិតថាមពលបែបរិមជ្ឈការ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន ទន្ទឹមគ្នានឹងការបំពេញតម្រូវការថាមពលនៅក្នុងប្រទេសកម្ពុជា និង រួមចំណែកដល់ការជម្រុញវិស័យសេដ្ឋកិច្ចប្រកបដោយចីរភាព។

អភិក្រមបច្ចុប្បន្នចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្នុងទូទាំងពិភពលោក និងនៅកម្ពុជា បានរួមចំណែកដល់ការធ្វើឱ្យបាត់បង់ ជីវៈចម្រុះជាច្រើន និង រួមចំណែកក្នុងការធ្វើឱ្យមានបម្រែបម្រួលធាតុអាកាស ដោយសារសកម្មភាពដូចជា ការសាងសង់រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មធំៗ ដែលធ្វើឱ្យកខ្វក់និងធ្វើឱ្យខូចខាតបរិស្ថាន និង ទំនប់វារីអគ្គិសនីធំៗដើម្បីផលិតអគ្គិសនី ជាដើម។ ម្យ៉ាងទៀត គម្រោង ទាំងនេះបានរួមចំណែកដល់ការកាប់ឆ្ការ

ព្រៃ និងដី ការប្រែប្រួលមិនអាចត្រឡប់ក្រោយចំពោះតំបន់ដីសើមនៃ ពិភពលោក ការបាត់បង់ជលផល និង មុខរបរ និង ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលនាំឱ្យមានបម្រែបម្រួលធាតុអាកាស។

ដើម្បីអភិរក្សជីវៈចម្រុះរបស់យើងឱ្យបានកាន់តែប្រសើរឡើង បណ្តាញវេទិកាបរិស្ថាននៅកម្ពុជា សូមអំពាវនាវដល់អ្នកធ្វើគោលនយោបាយ ដៃគូអភិវឌ្ឍន៍ និង ម្ចាស់ជំនួយ សូមឱ្យពិចារណាឡើងវិញអំពីគម្រោងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មកម្លាំង ១០០ មេហ្គាវ៉ាត់ដែលធ្វើឱ្យខូចខាតដល់បរិស្ថានដែលកំពុងត្រូវ បានសាងសង់នៅក្នុងស្រុក ស្ទឹងហាវ ខេត្តព្រះសីហនុ រួមជាមួយផែនការសាងសង់រោងចក្របន្ថែមនៅ ក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង។

ជំនួសការប្រើបច្ចេកវិទ្យាពីអតីតកាល ដូចជាការសាងសង់រោងចក្រដើរដោយធ្យូងថ្មដែលធ្វើឱ្យកខ្វក់បរិស្ថាន យើងអាចពិចារណាទៅលើវិធីសាស្ត្រដែលមានលក្ខណៈសន្សំសំចៃ និងអាចទុកចិត្តបានជាងក្នុងការផលិតអគ្គិសនី ដូចជា : ការផលិតអគ្គិសនីខ្នាតតូចនៅជិតទីកន្លែងដែលត្រូវការអគ្គិសនី ការប្រើបច្ចេកវិទ្យាផលិតថាមពលកកើតឡើងវិញប្រកបដោយនិរន្តរភាព ដូចជាបន្ទះអគ្គិសនីប្រើពន្លឺព្រះអាទិត្យ ថាមពលមកពីខ្យល់ វារីខ្នាតតូច ឧស្ម័នកម្ម ជីវៈម៉ាស ឬ រោងចក្រអគ្គិសនីវដ្តចម្រុះដើរដោយឧស្ម័ន។

នៅប្រទេសកម្ពុជានឹង ប្រារព្ធពិធីអបអរសាទរទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក នៅព្រឹកថ្ងៃទី ៤ ខែ មិថុនា ដោយមានការចូលរួមពី សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និង ស្ថាប័នរាជរដ្ឋាភិបាលចំនួនប្រហែល ១.០០០ នាក់។ ពិធីនេះនឹងរួមមានការដើរដង្ហែរក្បួន និង ការថ្លែងសុន្ទរកថា ដោយតំណាងមកពីក្រសួងបរិស្ថាន មន្ទីរបរិស្ថាន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល រួមជាមួយអភិបាលខេត្តព្រះសីហនុ។

បណ្តាញវេទិកាបរិស្ថាន និងបណ្តាញតស៊ូមតិនៃអង្គការមិនមែនរដ្ឋាភិបាលខេត្តព្រះសីហនុ (SNAN) រួមមានអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិប្រហែល៣0 ដែលធ្វើការងារដើម្បីដោះស្រាយបញ្ហាចំបងនានា ដែលប៉ះពាល់ដល់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិនៅប្រទេសកម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោក **ឈិត សំអាត** នាយកប្រតិបត្តិ អង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ១២ ៩២៨ ៥៨៥។ អ៊ីម៉ែល: ngoforum@ngoforum.org.kh

លោក **ប៊ុន ណារិទ្ធ** មន្ត្រីសម្របសម្រួល អង្គការលីកាដូ ខេត្តព្រះសីហនុ

ទូរស័ព្ទ: +៨៥៥ ១៥៩២ ៧៤៥។ អ៊ីម៉ែល: licadhosv@yahoo.com